# ព្រះរាជក្រម

នស/រកម/០២០២/០១០

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងសង្គមកិច្ច ការងារ បណ្តុះ-បណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារជម្រើសពីរ ដកស្រង់ពីអនុសញ្ញាស្តីពីសិទ្ធិកុមារ អំពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ និងអំពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងការផ្សព្វ-ផ្សាយរូបភាពអាសអាភាសកុមារ ដែលរដ្ឋសភាបានអនុម័តកាល ពីថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គ លើកទី ៧ នីតិកាលទី ២ ប៉ុន្តែដែលព្រឹទ្ធសភាពុំបានឱ្យយោបល់សោះ ព្រោះព្រឹទ្ធសភាពុំអាចដំណើរការប្រជុំពិនិត្យច្បាប់នេះបាន ដោយមូលហេតុខ្វះកូរ៉ុម។ ច្បាប់នេះមានសេចក្តីទាំងស្រុង ដូចតទៅ ៖

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើពិធីសារជម្រើសពីរ ដកស្រង់ពីអនុសញ្ញាស្តីពីសិទ្ធិកុមារ អំពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ និងអំពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងការផ្សព្វផ្សាយរូបភាពអាសអាភាសកុមារ

មាត្រា ១.-

អនុម័តយល់ព្រមលើពិធីសារជម្រើសពីរ ដកស្រង់ពីអនុសញ្ញាស្តីពីសិទ្ធិកុមារ អំពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ និងអំពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងការផ្សព្វផ្សាយរូបភាពអាសអាភាសកុមារ ដែលឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សបានអនុម័តយល់ព្រមនាសម័យប្រជុំពេញអង្គរបស់ខ្លួនលើកទី ៩៧ ព្រមទាំងបានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ចុះហត្ថលេខានៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០០ នៅទីក្រុងញូវយ៉ក ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារទាំងពីរនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០២

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

នស/រកម.០២.០២.០០៥៤

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា**

**អ៊ិត សំហេង**

លេខ : ៥៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង ទ៉ាន់**